មើលវីដេអូ ភាគទី ១៩

# ២៥ - បញ្ញិន្ទ្រិយចេតសិក ១ (Wisdom)

បជានាតីតិ = បញ្ញា ឈ្មោះថា បញ្ញា ព្រោះអត្ថថា ដឹងទូទៅ គឺ ដឹងអរិយសច្ចៈជាដើម បញ្ញានុ៎ះឯង ជាឥន្ទ្រិយ (ជាធំក្នុងការដឹងច្បាស់នូវសភាវធម៌) ព្រោះហេតុនោះ ទើបឈ្មោះថា បញ្ញិន្ទ្រិយ។

ស្កេនដើម្បីមើលមេរៀន

San Sochea Official

# លក្ខណាទិចតុក្កៈរបស់បញ្ញា

១ - ធម្មសភាវបដិវេធលក្ខណា

មានការចាក់ធ្លុះសភាវៈនៃធម៌ ជាលក្ខណៈ

២ - ធម្មានំ សភាវបដិច្ឆាទកមោហន្ធការវិទ្ធំសនរសា

មានការកំចាត់បង់នូវភាពងងឹត គឺមោហៈ ដែលបិទបាំងសភាវធម៌ជាកិច្ច

៣ - អសម្មោហបច្ចុប្បដ្ឋានា

មានការមិនវង្វេង ជាអាការប្រាកដ (ដូចមគ្គុទ្ទេសក៍ដ៏ចំណាន)

៤ - សមាធិបទដ្ឋានា មានសមាធិ ជាហេតុជិត។

# លក្ខណាទិចតុក្កៈរបស់បញ្ញា (ន័យម្យ៉ាងទៀត)

១ - យថាភូតបដិវេធលក្ខណា មានការចាក់ធ្លុះ (ដឹងច្បាស់) នូវធម៌តាមសេចក្ដីពិត ជាលក្ខណៈ

២ - វិសយោភាសនរសា មានការឆ្លុះបញ្ចាំងនូវអារម្មណ៍ឲ្យភ្លឺច្បាស់ ជាកិច្ច (ដូចប្រទីប ជាគ្រឿងបំភ្លឺ)

៣ - អសម្មោហបច្ចុប្បដ្ឋានា មានការមិនវង្វេង ជាអាការប្រាកដ

៤ - យោនិសោមនសិការបទដ្ឋានា មានយោនិសោមនសិការៈ ជាហេតុជិត។

តិហេតុកបដិសន្ធិកតាបទដ្ឋានា វា ឬមានតិហេតុកបដិសន្ធិ ជាហេតុជិត។

**បញ្ញាចេតសិក** នេះ កាលកើតឡើង រមែងដឹងទូទៅដល់ធម៌ទាំងដែលជា កុសល អកុសល ធម៌ដែលគួរសេព ធម៌ដែលមិនគួរសេព ដឹងធម៌ដែលអាក្រក់ ធម៌ដែលប្រណីត ធម៌ដែលចូលគ្នាបាន និងធម៌ដែលចូលគ្នាមិនបាន ដូចពេទ្យអ្នកមានជំនាញអាចផ្សំភេសជ្ជៈគឺថ្នាំ ដែលជាទីសប្បាយដល់អ្នកជម្ងឺជាដើម ដូច្នោះ ។